វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ក្រុមប្រឹក្សារដ្ឋមន្រ្តី

អនុក្រឹត្យ/០៦ អ.ន.ក្រ/០៦ ឧសភា ១៩៨៥/

ស្តីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញច្បាប់ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ១៩៨២
- បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៨៣ ស្តីពីសមត្ថកិច្ច និងនីតិវិធី នៃការធ្វើច្បាប់ និងបទបញ្ជា
- បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា លេខ ២៣៦.៨០ ស.រ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ១៩៨០ ស្តីអំពីការពង្រីកសេដ្ឋកិច្ចគ្រួសារ
- តាមសំណើរបស់ក្រសួងកសិកម្ម

សំរេច

ជំពូកទី១: បទប្បញ្ញត្តិទូទៅ

**មាត្រា១:**

ដីធ្លីកសិកម្មមាន ដីស្រែ វាលរាប ដីស្រែខ្ពង់រាប ដីទួល ដីព្រៃ ដែលមានការអនុញ្ញាត ដីចំការ ដីតាមមាត់ទន្លេ ដីកោះ វាលស្មៅធម្មជាតិ ទោះជាកំពុងដាំដុះ ឬទុកចោលទំនេរ និងបឹង ស្រះ ត្រពាំង ទំនប់ទឹក ដែលស្ថិតនៅក្រៅដែនទេសាទ ត្រូវគ្រប់គ្រងអោយបានម៉ត់ចត់ និងប្រើប្រាស់អោយបាន សមស្រប។

រដ្ឋអំណាចគ្រប់ថ្នាក់ មានភារកិច្ចគ្រប់គ្រង និងប្រើប្រាស់ដីធ្លីទូទៅ តាមព្រំប្រទល់ភូមិសាស្ត្ររដ្ឋបាលរបស់ខ្លួន។ ចំពោះតំបន់ណាដែលមិនទាន់បានកំណត់ព្រំប្រទល់ច្បាស់លាស់ ត្រូវរដ្ឋអំណាចមូលដ្ឋានតំបន់ នោះ ស្នើឡើងថ្នាក់លើដែលមានសមត្ថកិច្ចដើម្បីពិនិត្យ និងសំរេច។

ហាមឃាត់ការទិញ លក់ បញ្ចាំ ប្រវាស់ ជួលដី បឹង ឬជួលពលករធ្វើដី ទោះជាក្រោមរូបភាពណាក៏ដោយ។

ហាមផ្តាច់ការកាប់គាស់ រាន ឬឆ្ការព្រៃដោយគ្មានការអនុញ្ញាតយកទៅធ្វើស្រែចំការ ឬធ្វើអាជីវកម្ម ផលរ៉ែនៅក្នុងដី និងនៅកន្លែងដែលមានបេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រជាតិ។

**មាត្រា២:**

ក្រុមសាមគ្គីបង្កបង្កើនផល កសិដ្ឋានរដ្ឋ ស្ថានីយ៍ពិសោធន៍កសិកម្ម រុក្ខដ្ឋាន សាលាបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងផ្នែកនានា មានអាទិភាពក្នុងការប្រើប្រាស់ដីធ្លីដែលចែងក្នុងមាត្រា ១ ដើម្បីផលិតតាមផែនការកំណត់របស់រដ្ឋ។

ដីសំរាប់កសិកម្មមួយចំណែក ត្រូវបានប្រគល់អោយគ្រួសារកសិករ កម្មាភិបាល កម្មករ បុគ្គលិករដ្ឋ ដែលរស់នៅក្នុងមូលដ្ឋានផ្ទាល់ដើម្បីធ្វើសេដ្ឋកិច្ចគ្រួសារ និងសំរាប់ធ្វើលំនៅដ្ឋានតាមការកំណត់របស់រដ្ឋ។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ជំពូកទី២: ការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី

មាត្រា៣:

ក្រុមសាមគ្គីបង្កបង្កើនផល មានសិទ្ធិប្រើប្រាស់ដីកសិកម្មដូចតទៅ :

- ដីដែលរដ្ឋអំណាចបដិវត្តបានប្រគល់អោយក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩
- ដីដែលរដ្ឋអំណាចបដិវត្តបានអនុញ្ញាតអោយស្តារឡើងវិញ និងគាស់រានបន្ថែម
- ដីដែលរដ្ឋអំណាចបដិវត្តបានប្រគល់អោយប្រើប្រាស់ជាបណ្តោះអាសន្ន

ចំនួនផ្ទៃដីដែលប្រគល់អោយក្រុមសាមគ្គីបង្កបង្កើនផល ត្រូវគិតទៅតាមមធ្យមភាគនៃចំនួនប្រជាជន ទូទៅក្នុងឃុំ-សង្កាត់ រួមទាំងអ្នកចូលបំរើកងទ័ព នគរបាល កម្មាភិបាល កម្មករ បុគ្គលិករដ្ឋ និងជនពលី ដើម្បីបដិវត្តន៍ដែលមានឈ្មោះក្នុងបញ្ជីជំរឿនគ្រួសារនៅមូលដ្ឋាន។

**មាត្រា៤:**

កសិដ្ឋានរដ្ឋ មជ្ឈមណ្ឌលកសិកម្ម សាលាបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម មានសិទ្ធិ ប្រើប្រាស់ដីកសិកម្មដូចតទៅ :

- ដីដែលជាអតីតកសិដ្ឋានរដ្ឋ ស្ថានីយ៍ពិសោធន៍កសិកម្ម មជ្ឈមណ្ឌលកសិកម្ម សាលាបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដែលរដ្ឋអោយស្ថាបនា និងជួសជុលឡើងវិញ និងដីដែលរដ្ឋប្រគល់អោយដើម្បីពង្រីក និងស្ថាបនាបន្ថែម។
- ដីដែលរដ្ឋបានអនុញ្ញាតអោយស្តារឡើងវិញ ឬគាស់រានបន្ថែម។
- ដីដែលរដ្ឋអំណាចមូលដ្ឋានបានប្រគល់អោយប្រើប្រាស់ជាបណ្តោះអាសន្ន។

មូលដ្ឋាននៅក្រោមឱវាទផ្នែកផ្សេងៗ ដែលសុំដីសំរាប់ផលិតកម្ម ក៏ត្រូវបានប្រគល់ដីសំរាប់ប្រើប្រាស់ដែរ។

ចំនួនផ្ទៃដីដែលប្រគល់អោយមូលដ្ឋាននានាខាងលើ ត្រូវផ្អែកទៅតាមលទ្ធភាពនៃកំលាំងពលកម្ម និង សំណូមពរនៃការអភិវឌ្ឍរបស់ផ្នែក ដែលបានបញ្ចូលក្នុងផែនការរដ្ឋ។

**មាត្រា៥:**

គ្រួសារនានាមានលទ្ធភាពប្រើប្រាស់ប្រភេទដីកសិកម្មដូចតទៅ :

- ដីសំរាប់លំនៅដ្ឋាន និងដីសំរាប់ធ្វើសេដ្ឋកិច្ចគ្រួសារ "គិតទាំងចំការគ្រួសារ" ដែលរដ្ឋអំណាចបានប្រគល់ អោយប្រើប្រាស់តាមការកំណត់ និងតាមគោលនយោបាយរបស់រដ្ឋ។
- ដីបោះបង់ចោលទំនេរ ដែលរដ្ឋអំណាចបានអនុញ្ញាតអោយស្តារឡើងវិញ ឬគាស់រានបន្ថែម។
- ដីដែលក្រុមសាមគ្គីបង្កបង្កើនផលបានប្រគល់អោយប្រើប្រាស់បណ្តោះអាសន្ន។

ចំពោះគ្រួសារដែលឈប់បង្កបង្កើនផល ឬផ្លាស់លំនៅដ្ឋានទៅស្នាក់នៅមូលដ្ឋានផ្សេងៗទៀត ដោយមានមូលហេតុត្រឹមត្រូវ និងដោយរដ្ឋអំណាចមូលដ្ឋានអនុញ្ញាតយល់ព្រម គ្រួសារនោះត្រូវប្រគល់ដីដែលខ្លួនប្រើប្រាស់អោយរដ្ឋអំណាចឃុំ-សង្កាត់វិញ ដើម្បីប្រគល់អោយក្រុមសាមគ្គីបង្កបង្កើនផលប្រើប្រាស់។ រដ្ឋអំណាចមូលដ្ឋាននោះត្រូវជួយសំរុះសំរួលសមស្របចំពោះផលដំណាំ និងសំណង់របស់គ្រួសារនោះ។

ចំពោះដីដែលម្ចាស់មិនប្រើប្រាស់ រដ្ឋអំណាចមូលដ្ឋានមានភារកិច្ចគ្រប់គ្រង និងប្រគល់ជាបណ្តោះអាសន្ន អោយក្រុមសាមគ្គីបង្កបង្កើនផល ឬអោយគ្រួសារណាមួយ សំរាប់បង្កបង្កើនផល។

ចំពោះគ្រួសារកម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍ ហើយមានលទ្ធភាពបង្កបង្កើនផលកសិកម្មត្រូវបានរដ្ឋអំណាច មូលដ្ឋានប្រគល់ដីអោយមួយចំនួនដើម្បីប្រើប្រាស់។

វាយឡើងវិញជាភាសាខ្មែរពីឯកសារផ្លូវការ

ចំពោះជនរត់ចោលជួរខ្មាំង ហើយត្រឡប់មកជួបជុំជាមួយគ្រួសារវិញ បើចង់ចូលរួមបង្កបង្កើនផលកសិកម្ម ក៏មានសិទ្ធិប្រើប្រាស់ដីធ្លីដូចកសិករដទៃទៀតដែរ។

**មាត្រា៦:**

ដីសំរាប់បង្កបង្កើនផល ដើម្បីទ្រទ្រង់បេឡារបស់រដ្ឋអំណាច និងអង្គការមហាជននៅឃុំ-ភូមិ ដើម្បីប្រគល់អោយអង្គភាពចាត់តាំងរដ្ឋអំណាច អង្គការមហាជន ឈ្លប នគរបាលនៅឃុំ-ភូមិ បង្កបង្កើន ផល យកកំរៃសំរាប់ប្រើប្រាស់ក្នុងការងាររួម។

- ឃុំនីមួយៗអាចរក្សាទុកដីស្រែចំការមួយចំនួនមិនលើសពី ៦ហិកតា នៅកន្លែងណាដែលមានដីទូលាយ ហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើន នោះអាចរក្សាទុកដី ស្រែចំការចំនួន ៣ហិកតា។
- ភូមិនីមួយៗអាចរក្សាទុកដីស្រែចំការប្រមាណពី ១ ទៅ ២ហិកតា នៅកន្លែងណាដែលផ្ទៃដីទូលាយ ហើយមានមនុស្សតិច។ នៅកន្លែងណាដែលមានផ្ទៃដីតិច ហើយមានមនុស្សច្រើន នោះអាចរក្សាទុកដី ចំនួន ១ហិកតា។

គណៈកម្មាធិការប្រជាជនបដិវត្តស្រុក មានសមត្ថកិច្ចពិនិត្យនិងសំរេចលើចំនួនផ្ទៃដីខាងលើ ស្របតាមសភាពការណ៍ជាក់ស្តែងនៅ តំបន់នីមួយៗ។ ក្នុងករណីចង់យកចំនួនដីលើសពីការកំណត់ខាងលើ ត្រូវគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ពិនិត្យ និងសំរេច។

**មាត្រា៧:**

អំពីដីសំរាប់សាលារៀន :

ដើម្បីបង្កលក្ខណៈអោយសិស្សានុសិស្សចូលរួមពលកម្មដោយផ្ទាល់ ក្រៅពីដីសង់អាគារ និងទីធ្លា ត្រូវរក្សា ទុកដីមួយចំនួនសំរាប់សួនច្បារ យោលទៅតាមផ្ទៃដីតំបន់នីមួយៗ និងលទ្ធភាពពលកម្មរបស់សិស្ស។

**មាត្រា៨: អំពីដីវត្តអារាម :**

ដីដែលស្ថិតនៅក្នុងបរិវេណវត្តអារាម ត្រូវទុកអោយវត្តអារាមប្រើប្រាស់។

**មាត្រា៩: អំពីបឹង ស្រះ ថ្លុក ត្រពាំង ដែលស្ថិតនៅក្រៅដែននេសាទ :**

ចំពោះបឹង ស្រះ ថ្លុក ត្រពាំង ដែលស្ថិតនៅក្នុងភូមិ ឃុំណា ត្រូវភូមិ ឃុំនោះគ្រប់គ្រង និងប្រើប្រាស់រួម ដោយផ្តល់អាទិភាពដល់ប្រជាជនក្នុងការយកទឹកស្រោចដំណាំ និងចិញ្ចឹមត្រី តែប្រសិនបើស្រះ ថ្លុក ត្រពាំងនោះតូចតាចដែលបំរើសេដ្ឋកិច្ចគ្រួសារ ត្រូវទុកអោយគ្រួសារនោះប្រើប្រាស់។

ចំពោះបឹងធំៗដែលស្ថិតនៅក្រៅដែននេសាទ "ហើយមានការពាក់ព័ន្ធដល់ឃុំជាច្រើននៅក្នុងស្រុកតែមួយនោះ ត្រូវស្រុកគ្រប់គ្រង និងប្រើប្រាស់ ប្រសិនបើពាក់ព័ន្ធដល់ស្រុកច្រើន ត្រូវខេត្តគ្រប់គ្រង និង ប្រើប្រាស់"។

ការប្រើប្រាស់បឹងធំៗនេះ ត្រូវផ្អែកទៅលើទំលាប់របស់មូលដ្ឋានដែលបំរើផលប្រយោជន៍រួមរបស់ប្រជា ពលករ។

**មាត្រា១០: អំពីវាលស្មៅធម្មជាតិ :**

វាលស្មៅធម្មជាតិដែលស្ថិតនៅក្នុងមូលដ្ឋានណា ត្រូវរដ្ឋអំណាចមូលដ្ឋាននោះគ្រប់គ្រងសំរាប់សត្វ។

**មាត្រា១១: អំពីដីនៅទំនេរមិនទាន់បង្កបង្កើនផល :**

ដីកសិកម្មចោលទំនេរ និងដីមិនទាន់កាប់ឆ្ការស្ថិតនៅមូលដ្ឋានណា ត្រូវមូលដ្ឋាននោះមានផែនការប្រើប្រាស់ និងគ្រប់គ្រងអោយសមស្រប មិនត្រូវទុកអោយនៅទំនេរ ឬធ្វើជាកម្មសិទ្ធិរបស់បុគ្គលណាមួយ ឡើយ។

រដ្ឋត្រូវជួយឧបត្ថម្ភដល់ក្រុមសាមគ្គីបង្កបង្កើនផល កសិដ្ឋានរដ្ឋ ស្ថាប័ននានា ប្រជាជននៅទីក្រុង ទីរួមខេត្ត ក្នុងការស្តារដីចោលទំនេរ និងរានដីថ្មីដើម្បីពង្រីកផលិតកម្មកសិកម្ម។ អ្នកដែលបានសុំស្តារដី ឬ រានដីថែម គឺគ្មានបង់ប្រាក់អ្វីទាំងអស់។ ការអនុញ្ញាតអោយខ្ទីដីសំរាប់បង្កបង្កើន

ផលលើផ្ទៃដីដែលមិនទាន់ដាំដុះដូចខាងលើ ត្រូវមានរយៈពេលកំណត់ពី ៣ ទៅ ៥ឆ្នាំ យោលទៅលើកំលាំងពលកម្ម សំភារៈដែលចំណាយទៅលើការងារនោះ ។ ត្រូវបានលើកលែងវិភាគទានស្នេហាជាតិក្នុងរយៈពេល ២ឆ្នាំ ចំពោះដី ដែលបានស្តារឡើងវិញ និង ៥ឆ្នាំ ចំពោះដីទើបបានរានថ្មី ។

**មាត្រា១២: អំពីដីស្ថាបនាសំណង់ :**

ការផ្តល់ដីសំរាប់ស្ថាបនាសំណង់នានា ត្រូវសំរេចដោយក្រុមប្រឹក្សារដ្ឋមន្ត្រី ឬគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ដោយផ្អែកលើគំរោងប្លង់នៃ សំណង់ដែលស្ថាប័នមានសមត្ថកិច្ចបានសំរេច ។

ការផ្តល់ដីសំរាប់ស្ថាបនាសំណង់នៅក្នុងភូមិ ឃុំ សង្កាត់ ត្រូវគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង សំរេចតាមសំណើរបស់គណៈកម្មាធិការប្រជាជនបដិវត្តស្រុក-ខណ្ឌ ទីរួមខេត្ត ឃុំ សង្កាត់ ។

ការយកដីសំរាប់ស្ថាបនាសំណង់ ត្រូវជូនដំណឹងទៅអ្នកកាន់កាប់ដីនោះមួយរដូវបង្កបង្កើនផលជាមុន ម្ចាស់សំណង់ថ្មីនេះ ត្រូវសហការជាមួយរដ្ឋអំណាចមូលដ្ឋានក្នុងការសំរបសំរួលចំពោះការបង់ខាតរបស់ អ្នកកាន់កាប់នោះ ។

**មាត្រា១៣: អំពីសិទ្ធិផ្តល់ដីសំរាប់សំណង់ :**

- គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង មានសមត្ថកិច្ចផ្តល់ដីពី ៥ហិកតា ចុះមក ។
- ការផ្តល់ដីពី ៥ហិកតាឡើងទៅ ជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

**មាត្រា១៤: អំពីការខ្ចីដីសំរាប់បង្កបង្កើនផល :**

- ចំពោះមូលដ្ឋានណាដែលមានដីច្រើន រួមទាំងដីសំណង់ចាស់បោះបង់ចោល ហើយពុំទាន់មានលទ្ធភាពធ្វើអស់ផ្ទៃដី ត្រូវអោយមូលដ្ឋានផ្សេងៗទៀតដែលខ្វះដី ខ្ចីដី ដើម្បីបង្កបង្កើនផល ។
- ក្រុមសាមគ្គីបង្កបង្កើនផលដែលធ្វើមិនអស់ផ្ទៃដី ត្រូវអោយគ្រួសារសមាជិកក្រុម ឬក្រុមផ្សេងៗទៀត ខ្ចីដីដែលសល់ដើម្បីបង្កបង្កើនផល ។ ក្រោយពេលប្រមូលផលរួចហើយ ត្រូវសងដីនោះអោយក្រុមសាមគ្គី វិញ ។

## ជំពូកទី៣: ទោសប្បញ្ញត្តិ

**មាត្រា១៥:**

ជនណាទិញ លក់ បញ្ចាំ ប្រវាស់ ជួលដី បឹង ឬជួលពលករធ្វើដី បឹង ទោះក្រោមរូបភាពណា ក៏ដោយ ត្រូវផ្តន្ទាទោសតាមច្បាប់រដ្ឋបាល ។

**មាត្រា១៦:**

ជនណាកាប់គាស់រាន ឬឆ្ការព្រៃ ដោយគ្មានការអនុញ្ញាតយកទៅធ្វើស្រែចំការ ឬធ្វើអាជីវកម្មផលរ៉ែនៅក្នុងដី និងនៅកន្លែងដែលមានបេតិកភ័ណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ត្រូវទទួលទោសតាម ច្បាប់ជាធរមាន ។

## ជំពូកទី៤: បទប្បញ្ញតិជាអវសាន

**មាត្រា១៧:**

ក្រសួងកសិកម្ម គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា១៨:**

អនុក្រឹត្យនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃដែលប្រកាសផ្សាយជាសាធារណៈ ។